Australian Government
AusAID

Australian AID

# សេចក្តីសង្ខេបគោលនយោបាយស្រាវជ្រាវ

## ហានិភ័យត្រីគុណ៖ អំពើហិង្សាចំពោះស្ត្រីពិការក្នុងប្រទេសកម្ពុជា

## ការកំណត់បញ្ហា

ស្ត្រីពិការ នៅលើពិភពលោក ជួបប្រទះបញ្ហាអំពើហិង្សាក្នុងកម្រិតខ្ពស់ខ្លាំងជាងស្ត្រីមិនពិការ ។ ពួកគាត់ទទួលរងគ្រោះទាំងសុខភាពផ្លូវកាយ និងផ្លូវចិត្តធ្ងន់ធ្ងរដោយសារការបង្កពីអំពើហិង្សា ហើយពួកគាត់ស្ថិតក្នុងកម្រិត ហានិភ័យខ្ពស់នៃការជួបនឹងបញ្ហាស្លាកស្នាមទុយ៌ស ការរើសអើង និងការរំលោភសិទ្ធិផ្សេងៗទៀត ។ ប៉ុន្តែមានទិន្នន័យតិចតួចអំពីពិការភាព និងភេទ ទាក់ទងនឹងអំពើហិង្សាអន្តរបុគ្គលបានបញ្ចូលទៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ។

## សារសំខាន់ៗ

- ស្ត្រីពិការនៅក្នុងប្រទេសកម្ពុជា ជួបប្រទះនូវ ឥរិយាបទគ្របសង្កត់ក្នុងកម្រិតខ្ពស់ពីដៃគូជិតស្និទ្ធ និងរងអំពើហិង្សាគ្រប់រូបភាព (ផ្លូវចិត្ត ផ្លូវកាយ និងផ្លូវភេទ) ពីសមាជិកគ្រួសារ បើប្រៀបធៀបជាមួយស្ត្រីមិនមែនពិការ ។
- ស្ត្រីពិការ ដែលបានចូលរួមនៅក្នុងការសិក្សានេះ ត្រូវបានកត់ត្រានូវអត្រាអំពើហិង្សាក្នុងគ្រួសារមានស្ថិតិខ្ពស់ជាងស្ត្រីមិនពិការ
    - ៥២,៥% រងការរំលោភផ្លូវចិត្ត
    - ២៥,៥% រងការរំលោភផ្លូវកាយ
    - ៥,៧% រងការរំលោភផ្លូវភេទពីសមាជិកគ្រួសារ
- ស្ត្រីពិការជួបវិបត្តិផ្លូវចិត្តច្រើនជាងស្ត្រីមិនពិការ ដោយមិនគិតពីការរងអំពើហិង្សា
- ឧបសគ្គក្នុងការលាតត្រដាងពីអំពើហិង្សា និង ការទទួលបានសេវាគឺមានលក្ខណៈមិនល្អដោយសារ ស្ត្រីពិការមានភាពទន់ខ្សោយផ្នែកហិរញ្ញវត្ថុ និង អំណាចតិចតួចនៅក្នុងជីវិតរបស់ពួកគាត់
- មានតម្រូវការបន្ទាន់មួយក្នុងការលើកកម្ពស់គោលនយោបាយ និងសេវាកម្ម ដើម្បីបញ្ឈប់អំពើហិង្សា និងការរើសអើង ដែលជួបប្រទះដោយស្ត្រីពិការ។

*ហានិភ័យត្រីគុណ (Triple Jeopardy)* ជាគម្រោងស្រាវជ្រាវរយៈពេលបីឆ្នាំត្រូវបានធ្វើការសិក្សាដើម្បីផ្តល់នូវព័ត៌មានប្រៀបធៀបអំពីជីវិតរស់នៅរបស់ស្ត្រីពិការនៅក្នុងប្រទេសកម្ពុជា ។

## បទពិសោធន៍នៃអំពើហិង្សា

លទ្ធផលបង្ហាញថាគ្មានភាពខុសគ្នាខ្លាំង ផ្នែកអត្រាដែលជួបប្រទះអំពើហិង្សាលើរាងកាយឬ ហិង្សាផ្លូវភេទពីដៃគូរឡើយ រវាងស្ត្រីពិការ និងស្ត្រីមិនពិការ ។ ប៉ុន្តែស្ត្រីពិការទំនងជាជួបប្រទះនូវការដាក់កម្រិតសកម្មភាព និងទីកន្លែងរបស់ពួកគាត់ ពីសំណាក់ដៃគូ ៤,២ ដងច្រើនជាងស្ត្រីមិនពិការ ។

លទ្ធផលនៃការវិភាគទាំងបែបបរិមាណ និង គុណភាពទៅលើអំពើហិង្សាក្នុងចំណោមស្ត្រីពិការបានបង្ហាញថា ស្ត្រីពិការជួបប្រទះអំពើហិង្សាផ្នែកផ្លូវចិត្ត ផ្លូវកាយ ផ្លូវភេទកំរិតខ្ពស់ពីណាក់សមាជិកគ្រួសារ ជាងពីដៃគូរ បើប្រៀបធៀបជាមួយស្ត្រីមិនពិការ។

ជាងហាសិបភាគរយឬ៥២,៥ ភាគរយនៃអ្នកចូលរួមជាស្ត្រីពិការបានរាយការណ៍ ពីកាទទួលរងអំពើហិង្សាលើផ្លូវចិត្ត ប្រៀបធៀបជាមួយស្ត្រីមិនពិការ ៣៥,២% ។ មួយភាគបួនរឺ២៥,៤%នៃស្ត្រីពិការបានរាយការណ៍អំពីអំពើហិង្សាលើផ្លូវកាយ (ធៀបជាមួយ១១,៤%នៃស្ត្រីមិនពិការ)។ ៥,៧ ភាគរយរាយការណ៍ពីអំពើហិង្សាផ្លូវភេទពីសមាជិកគ្រួសារ(ធៀបជាមួយ១,១%នៃស្ត្រីមិនពិការ)។ ទាំងនេះបន្ថែមទៅលើការទទួលរងការគ្រប់គ្រង និងការគម្រាមកំហែងផ្នែកឥរិយាបទដូចជា ការសុំការអនុញ្ញាតពីមនុស្សក្នុងគ្រួសារមុនទៅទទួលការថែទាំសុខភាព។ ការសិក្សាបានរកឃើញពីការទាក់ទងគ្នាយ៉ាងច្បាស់រវាងអំពើហិង្សា និងពិការភាព និងកម្រិតកើនឡើងនៃបញ្ហាផ្លូវចិត្ត ។ ទោះជាយ៉ាងណាក៏ដោយ ស្ត្រីពិការ ជួបប្រទះនូវបញ្ហាផ្លូវចិត្តខ្ពស់ជាងស្ត្រីមិនពិការ ដោយមិនគិតពីកម្រិតប្រឈម

នឹងអំពើហិង្សាផ្សេងទៀតឡើយ ។ នេះបានគូសបញ្ជាក់ពីសម្ពាធនៃបញ្ហាផ្លូវចិត្តដែលជួបប្រទះដោយស្ត្រីពិការក្នុងប្រទេសកម្ពុជា ។

## ឧបសគ្គចំពោះការលាតត្រដាងពីអំពើហិង្សា និងការទទួលបានសេវាគាំទ្រ

ស្ត្រីដែលបានចូលរួមមួយចំនួនតូច បានលាតត្រដាងអំពីបញ្ហា អំពើហិង្សាដល់មនុស្សជុំវិញខ្លួន ឬស្វែងរកសេវាគាំទ្រ មិនថាពួកគេជាជនពិការឬមិនពិការក៏ដោយ ។ ស្ត្រីពិការ ហាក់បីដូចជាមានការលាតត្រដាងពីបញ្ហាអំពើហិង្សាពីដៃគូរតិចជាង បើប្រៀបធៀបជាមួយស្ត្រីមិនពិការ។ ឧបសគ្គក្នុងការលាតត្រដាងពីអំពើហិង្សា និងការស្វែងរកសេវាកម្មគាំទ្រពីសមាជិកគ្រួសារ មានលក្ខណៈធ្ងន់ធ្ងរចំពោះគ្រប់ស្ត្រីទាំងអស់ជាជាងពីដៃគូរ។ ឥទ្ធិពលអវិជ្ជមាននៃអំពើហិង្សានិង ពិការភាពមានស្ថានភាពរឹតតែអាក្រក់សម្រាប់ស្ត្រីពិការដែលមានស្វ័យភាពហិរញ្ញវត្ថុទាប ភ្នាក់ងារជំនួយតិចតួចនៅក្នុងជិវិតរបស់ពួកគាត់ជាងស្ត្រីមិនពិការ។

## ទិសដៅគោលនយោបាយ

បច្ចុប្បន្ននេះ នៅក្នុងប្រទេសកម្ពុជា នៅមិនទាន់មានគោលនយោបាយណាមួយ ដែលអាចដោះស្រាយគ្រប់ប្រភេទនៃអំពើហិង្សាជាក់លាក់ ដែលជួបប្រទះដោយស្ត្រីពិការ ឬមានច្បាប់គាំទ្រ ការតស៊ូមតិ ឬសេវាផ្តល់ជម្រកសម្រាប់ពួកគាត់ឡើយ ។ មានតម្រូវការជាបន្ទាន់មួយក្នុងការកែប្រែឥរិយាបទរើសអើង និងការបង្កើនការយល់ដឹងពីស្ថានភាពស្ត្រីពិការផងដែរ។ បន្ថែមពីនេះ ការសិក្សាបានរំលេចពីទិសដៅគោលនយោបាយសំខាន់ៗមួយចំនួន៖

*តម្រូវការជាក់លាក់របស់ស្ត្រីពិការដែលបានជួបប្រទះបញ្ហាអំពើហិង្សា៖*

សេវាកម្មដែលអាចរកបានច្រើនបំផុត គឺផ្តោតលើតម្រូវការរបស់ស្ត្រីដែលបានជួបប្រទះអំពើហិង្សាពីដៃគូ។ ស្ត្រីពិការក្នុងប្រទេសកម្ពុជាហាក់ដូចជាមិនមានដៃគូធៀបជាមួយស្ត្រីមិនពិការ ក៏ទំនងជាជួបបញ្ហាអំពើហិង្សាក្នុងគ្រួសារកាន់តែខ្ពស់ដែរ ពីសំណាក់សមាជិកក្នុងគ្រួសារ ។ គោលនយោបាយ និងកម្មវិធីស្តីពីអំពើហិង្សា ត្រូវតែធ្វើការកែច្នៃដើម្បីឆ្លើយតបចំពោះភាពខុសគ្នានេះ ។

*ការចូលរួមយ៉ាងខ្លាំងក្លា របស់ស្ត្រីពិការក្នុងការធ្វើផែនការ និងការផ្តល់សេវាដើម្បីជួបតម្រូវការជាក់លាក់៖*

ស្ត្រីពិការ កម្រក្លាយជាអ្នកដឹកនាំ ឬជាអ្នកសម្រេចចិត្តនៅក្នុងអង្គការជនពិការឡើយ ។ អវត្តមាននៃសម្លេងនេះ មិនត្រឹមតែជះឥទ្ធិពលដល់អាទិភាពនៃអង្គការប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចត្រូវបានគេមើលរំលងដល់ បទពិសោធន៍យេនឌ័ររបស់ជនពិការ ឬក៏ឧបសគ្គដោយឡែកដែលប្រឈមដោយស្ត្រីពិការ នៅពេលបង្កើតគោលនយោបាយឬកម្មវិធី ។

*ការកែប្រែឥរិយាបទ និងអាកប្បកិរិយាដែលគាំទ្រ ប្រឆាំងនឹងអំពើហិង្សា៖*

ការប្រយុទ្ធប្រឆាំងជាមួយឥរិយាបទរើសអើង ដែលខុសឆ្គង ហើយដែលនាំឲ្យមាន អំពើហិង្សាចំពោះស្ត្រីពិការ ត្រូវការឲ្យមានការចូលរួមផ្នែកគោលនយោបាយរយៈពេលយូរ និងស្ថិតស្ថេរ ដោយផ្អែកយ៉ាងមុតមាំទៅលើសិទ្ធិមនុស្ស និងវិធីសាស្ត្រធ្វើការផ្លាស់ប្តូរយេនឌ័រដែលមានភាពមិនស្មើគ្នាដើម្បី លើកកម្ពស់ការចែករំលែកអំណាច ការគ្រប់គ្រងធនធាន និងការសំរេចចិត្ត ។

## ការផ្តល់អនុសាសន៍នានា ទៅលើផ្នែកគោលនយោបាយ និង កម្មវិធី

ដោយផ្អែកលើទិសដៅគោលនយោបាយទាំងនេះ ការសិក្សាសូមផ្តល់អនុសាសន៍មួយចំនួន៖

*ការកំនត់មូលនិធិគោលដៅ ដើម្បីដោះស្រាយភាពខ្វះចន្លោះនិងលើកកម្ពស់គោលនយោបាយ និង កម្មវិធី៖*

- ផ្តោតលើការផ្តួចផ្តើមដែលបង្ហាញពីការប្រសព្វគ្នានៃយេនឌ័រ និងពិការភាព
- គាំទ្រគោលនយោបាយ និងកម្មវិធីរបស់អង្គភាពព្រាបដែលកំណត់ និងផ្តល់សេវាទៅដល់ស្ត្រីពិការ
- ផ្តល់គម្រោងហិរញ្ញវត្ថុដែលទទួលស្គាល់ និងពិចារណាទៅដល់ភាពចម្រុះរបស់ស្ត្រីពិការ (ឧទាហរណ៍ សមាជិកភាពនៃក្រុមជនជាតិភាគតិច)

*ពង្រឹងគោលនយោបាយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និង ពិការភាព និង លើកកម្ពស់ការឆ្លើយតបជាលក្ខណៈស្ថាប័ន៖*

- ផែនការសកម្មភាពជាតិដើម្បីទប់ស្កាត់អំពើហិង្សាលើស្ត្រី ស្ថិតក្នុងដំណើរការបង្កើត) គួរតែបញ្ចូល យុទ្ធសាស្ត្រជាក់លាក់ដើម្បីការពារគ្រប់ទំរង់នៃអំពើហិង្សាលើស្ត្រីពិការ ដែលរួមមានអំពើហិង្សាពីសមាជិកគ្រួសារ និងបង្កើនការទទួលស្គាល់ថាពិការភាពធ្វើឲ្យស្ត្រីកាន់តែងាយរងគ្រោះពីអំពើហិង្សា។
- សហការណ៍កាន់តែជិតស្និតរវាងអ្នកបង្កើត គោលនយោបាយដែលផ្តោតលើពិការភាព និងយេនឌ័រ នឹងជួយឆ្លុះបញ្ចាំងពីចំណុចប្រសព្វ។
- ភ្នាក់ងារមិនមែនរដ្ឋាភិបាល និងភ្នាក់ងាររដ្ឋាភិបាល ដែលពាក់ព័ន្ធនៅក្នុងគោលនយោបាយពិការភាព និងយេនឌ័រ គួរកំណត់អាទិភាពធ្វើការវាយតម្លៃសកម្មភាពនៅក្នុងកម្ម

វិធី និង ដំនើរការ នៃពិការភាព និងយេនឌ័រ ។

- អង្គការ និងអ្នកផ្តល់សេវាកម្ម ត្រូវតែស្វែងយល់ឲ្យច្បាស់ពីរបៀបដែលយេនឌ័រជះឥទ្ធិពលដល់ បទពិសោធន៍របស់ពិការភាព និងទៅវិញទៅមក និងធ្វើការពិនិត្យឡើងវិញលើកម្មវិធីដើម្បីឆ្លុះបញ្ចាំងពីតម្រូវការ និងអាទិភាពដ៏ជាក់លាក់របស់ស្ត្រី និងបុរសពិការ ។
- ការពិនិត្យឡើងវិញលើកម្មវិធី និងសេវាកម្មដែលមានស្រាប់ដែលទាក់ទងទាំងស្ត្រី និងបុរសពិការ ។

*ការបង្ការអំពើហិង្សា៖*

- កំណត់សកម្មភាពអប់រំដើម្បីប្រយុទ្ធប្រឆាំងនឹង ការរើសអើង ការបង្កើនសមត្ថភាពរបស់មនុស្សក្នុងការកំណត់ អំពើហិង្សា ការធ្វើការគាំទ្រដល់អ្នកដែលជួបនឹងបញ្ហាអំពើហិង្សា ការជួយជម្រុញការគាំទ្រ និងការជួយស្វែងរកបណ្តាញជំនួយដែលត្រូវបានអនុវត្តនៅក្នុងសហគមន៍ ។
- អង្គភាព និង អ្នកផ្តល់សេវាកម្ម ត្រូវដោះស្រាយបញ្ហាប្រឈមដែលជួបប្រទះដោយស្ត្រីពិការ ដោយរួមមាន ការផ្តោតទៅលើអំពើហិង្សាពីសមាជិកគ្រួសារ ការប្រឹក្សាយោបល់ ទៅលើវិបត្តិរយៈពេលយូរ ដើម្បីដោះស្រាយបញ្ហាផ្លូវចិត្តកម្រិតខ្ពស់ និង ស្វែងរកវិធីដើម្បីបង្កើនការទទួលការថែទាំសុខភាព ។
- លើកកម្ពស់ស្ត្រីពិការ តាមរយៈការអប់រំទៅលើ សិទ្ធិផ្នែកផ្លូវភេទ និងសុខភាពបន្តពូជ ដែលអាចមានឥទ្ធិពលខ្លាំងទៅលើលទ្ធភាពក្នុងការគ្រប់គ្រងជម្រើសក្នុងជីវិត និងបង្កើនសុខុមាលភាព ។
- កម្មវិធីអំពើហឹង្សាទាក់ទងនឹងយេនឌ័រ គួរពិចារណា និង ដោះស្រាយហេដ្ឋារចនាសម្ព័ន្ធ ការទំនាក់ទំនង ឬឧបសគ្គផ្សេងៗក្នុងការទទួលបានសេវាជំនួយ ដែលប្រឈមមុខដោយស្ត្រីពិការ ។
- អជ្ញាធរមូលដ្ឋាន ប៉ូលីស និងតុលាការ គួរត្រូវបានទទួលការបណ្តុះបណ្តាលស្តីពី សិទ្ធិជនពិការ ដើម្បីលើកកំពស់ការអនុវត្តន៍ច្បាប់ដែលមានស្រាប់ ។

## ការអានបន្ថែម

Walji, F "ការដាក់បញ្ចូលស្ត្រីពិការទៅក្នុងគោលនយោបាយយេនឌ័រ និងពិការភាព៖ ការឆ្លុះបញ្ចាំងបទពិសោធន៍នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក "*Journal for Disability and International Development*, 3. 2009 ។

- ក្រុមស្រាវជ្រាវ បានបង្កើតឧបករណ៍បណ្តុះបណ្តាលមួយចំនួនដែលមានតម្លៃទាប ដែលអាចទាញយកបាន ទាំងភាសាអង់គ្លេស និង ភាសាខ្មែរដោយសេរីពីបណ្តាគេហទំព័ររបស់អង្គការបន្ទាយស្រី (Banteay Srei), ការស៊ីប៊ីអិម អូស្ត្រាលី (CBM Australia) អង្គជនពិការកម្ពុជា (CDPO) និងនារីអន្តរជាតិដើម្បីអភិវឌ្ឍ( IWDA) ។

**ក្រុមអ្នកស្រាវជ្រាវ៖** អង្គការបន្ទាយស្រី អង្គការជនពិការកម្ពុជា (CDPO) អង្គការCBM Australia អង្គការនារីអន្តរជាតិដើម្បីអភិវឌ្ឍ (IWDA) និងសាកលវិទ្យាល័យ Monash ។

**ក្រុមអ្នកកែសម្រួល៖** Nina Vallins និង Fareen Walji

**ឯកសារនេះ គឺជាលទ្ធផលពីការសិក្សាស្រាវជ្រាវដែលត្រូវបានឧបត្ថម្ភដោយ AusAID ។ ទស្សន: និងគំនិតដែលបង្ហាញនៅក្នុងឯកសារនេះគឺជារបស់ម្ចាស់អត្ថបទ និងមិនសុទ្ធសឹងតែបានឆ្លុះបញ្ចាំងពីទស្សន:របស់ AusAID ឬរដ្ឋាភិបាលអូស្ត្រាលីឡើយ ។**

www.ausaid.gov.au